ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៩៥......សហវ.ប្រក

# ប្រកាស
## ស្តីពីការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា
## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ០២ សរណន ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១** : បង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. | ឯកឧត្តម **ទេរី វិស្សុត** អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម **ទង់ សណ្តាប់** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៥. | ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦. | ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៧. | លោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៨. | លោកប្រធាននាយកដ្ឋានថវិកា | សមាជិក |
| ៩. | លោកប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១០. | លោកប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | សមាជិក |
| ១១. | លោកប្រធាននាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| ១២. | លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៣. | លោកប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៤. | លោកប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ១៥. | លោកប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៦. | លោកប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៧. | លោកប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៨. | លោកប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៩. | លោកប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ២០. | លោកប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន | សមាជិក |
| ២១. | លោកប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | សមាជិក |

២២. លោកប្រធាននាយកដ្ឋាននីតិកម្ម សមាជិក

២៣. លោកអគ្គាធិការនៃអគ្គាធិការដ្ឋាន សមាជិក

២៤. លោកនាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២៥. លោក **អេង ធូច** ជំនួយការឯកឧត្តមអគ្គលេខាធិការ លេខាធិការ

២៦. លោក **ស៊ុនលី ធារិទ្ធ** ជំនួយការឯកឧត្តមអគ្គលេខាធិការ លេខាធិការ

២៧. លោក **គីម សុធារិទ្ធ** ជំនួយការឯកឧត្តមអគ្គលេខាធិការ លេខាធិការ

**ប្រការ ២** : ក្រុមការងាររៀបចំផែនការយុទ្ធសាស្រ្តថវិកា របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចរៀបចំផែនការយុទ្ធសាស្រ្តថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយជូនថ្នាក់ដឹកនាំក្រសួង ពិនិត្យ និង សម្រេច ឱ្យបានទាន់កាលវសាន្តកំណត់ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង សារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ។

**ប្រការ ៣** : ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃក្រុមការងារ ត្រូវបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។ អនុប្រធាន និង សមាជិកទាំងអស់ នៃក្រុមការងារ ត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៤** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០

គាត ឈន់

**<u>កន្លែងទទួល</u>:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ ១
- ឯកសារ- កាលប្បវត្តិ